I- ឯកសាររាជការព្រះមហាក្សត្រ

១- ព្រះរាជក្រម

ព្រះរាជក្រម នស/រកម/១២៩៧/០៦

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត-០៨៩៧-១៤៨ ចុះថ្ងៃទី០៧ ខែសីហាឆ្នាំ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស.រកម-០១៩៦-០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស-រកម-១១៩៧-០៧ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ស្តីពី...បក្សនយោបាយ

- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ប្រកាសអោយប្រើ**

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលសភាបានអនុម័តកាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូច តទៅ :

# ច្បាប់
# ស្តីពី
# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ច្បាប់នេះមានគោលដៅកំណត់អង្គការរៀបចំការបោះឆ្នោត បែបបទនិងការប្រព្រឹត្តិទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលជាសមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .-**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវអនុវត្តតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

**មាត្រា ៣ .-**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងប្រាំឆ្នាំម្តង នៅថ្ងៃអាទិត្យ នៃសប្តាហ៍ទី៨ មុនដំណាច់ឆ្នាំទី៥ នៃនីតិកាលរបស់រដ្ឋសភា លើកលែងតែក្នុងស្ថានភាពណា មួយដូចខាងក្រោម :

-ក្នុងករណីប្រធានស័ក្តិដែលចាំបាច់ត្រូវលើកថ្ងៃបោះឆ្នោត ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ។ ក្នុងករណីនេះការបោះឆ្នោតជ្រើសរើសរដ្ឋសភាថ្មីត្រូវប្រព្រឹត្តទៅក្នុងរយៈពេលហុកសិប(៦០)ថ្ងៃយ៉ាងយូរចាប់ចាត់ពីថ្ងៃរំលាយរដ្ឋសភា ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានប្រកាសអោយបន្តនីតិកាលរបស់ខ្លួនស្របតាម វាក្យខ័ណ្ឌទី ៥ មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ៤..**

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់នេះ ។

## ជំពូកទី ២

## ប្រព័ន្ធបោះឆ្នោតនិងការកំណត់អាសនៈ

**មាត្រា ៥ ..**

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមខេត្ត ក្រុង ដោយយកខេត្ត ក្រុង ជាមណ្ឌលបោះឆ្នោត ។

**មាត្រា ៦ ..**

អាសនៈនៅក្នុងរដ្ឋសភាមានចំនួនយ៉ាងតិច មួយរយម្ភៃ (១២០) ។

**មាត្រា ៧ ..**

រៀងរាល់ឆ្នាំទី៣ នៃនីតិកាលរបស់រដ្ឋសភា គណៈរដ្ឋមន្ត្រីត្រូវបង្កើតគណៈកម្មការកំណត់អាសនៈរដ្ឋសភា ដើម្បីធ្វើការកែប្រែចំនួនអាសនៈ និង បែងចែកអាសនៈតាម ខេត្ត ក្រុង ។

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម :

-តំណាងមួយរូបនៃគណបក្សនយោបាយនីមួយៗដែលមានអាសនៈក្នុងរដ្ឋសភា ។

-តំណាងក្រសួងមហាផ្ទៃពីររូប ។

-នាយកនៃវិទ្យាស្ថានជាតិស្ថិតិ ។

គណៈកម្មការនេះដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយរូប ដែលជ្រើសតាំងក្នុងចំណោមសមាជិកគណៈកម្មការ ដោយការបោះឆ្នោតតាមមតិភាគច្រើនដាច់ ខាតពីសមាជិកគណៈកម្មការនេះ ។

គណៈកម្មការនេះត្រូវធ្វើរបាយការណ៍ និង លើកសំណើអំពីការបន្ថែមអាសនៈ ឬការរក្សាទុកចំនួនអាសនៈនៅដដែលជូនរាជរដ្ឋាភិបាល ដោយផ្អែកលើស្ថានភាពប្រជាពលរដ្ឋ ស្ថានភាពភូមិសាស្ត្រសង្គមនិងសេដ្ឋកិច្ច ។

រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីព្រាងច្បាប់ស្តីពីការកំណត់ចំនួនអាសនៈនេះ ជូនរដ្ឋសភាអនុម័ត ។

ក្នុងករណីខកខានពុំបានកំណត់ជាថ្មីនូវចំនួនអាសនៈក្នុងរដ្ឋសភា ចំនួនអាសនៈនោះត្រូវយកតាមចំនួនអាសនៈរដ្ឋសភាដែលមានក្នុងនីតិកាលចុងក្រោយ ។

**មាត្រា ៨ .-**

ចំនួនអាសនៈដែលត្រូវមាននៅក្នុងរដ្ឋសភា និងចំនួនអាសនៈដែលត្រូវបែងចែកតាមខេត្ត ក្រុង ត្រូវផ្សព្វផ្សាយជាសាធារណៈ យ៉ាងតិចមួយឆ្នាំមុនថ្ងៃបោះឆ្នោត ។

**មាត្រា ៩ .-**

ក្នុងការរកចំនួនអាសនៈថ្មីរបស់រដ្ឋសភា ត្រូវគណនាតាមរូបមន្តដូចខាងក្រោមដោយមិនគិតចំនួនសល់ :

$$\frac{\text{ប}_{\text{ម}}}{\text{ច}_{\text{ម}}} = \text{ផ}$$

-$\text{ប}_{\text{ម}}$ ជាចំនួនប្រជាពលរដ្ឋខ្មែរនៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយកន្លងមកនេះ ។

-$\text{ច}_{\text{ម}}$ ជាចំនួនអាសនៈក្នុងរដ្ឋសភាបច្ចុប្បន្ន ។

-ផ ជាផលចែកប្រភាគដោយពុំគិតចំនួនសល់ ។

$$\frac{\text{ប}_{\text{ប}}}{\text{ផ}} = \text{ច}_{\text{ថ}}$$

-$\text{ប}_{\text{ប}}$ ជាចំនួនប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ន ។

-$\text{ច}_{\text{ថ}}$ ជាចំនួនអាសនៈថ្មី ដោយពុំគិតចំនួនសល់ ។

ក្នុងការរកចំនួនអាសនៈតាមខេត្ត ក្រុង ត្រូវគណនាតាមរូបមន្តដូចខាងក្រោម :

$$\frac{\text{ប}}{\text{ផ}} = \text{ច}$$

-ប ជាចំនួនប្រជាពលរដ្ឋខ្មែរក្នុងខេត្ត ក្រុង ។

-ផ ជាផលចែកប្រភាគដែលបានមកពីការគណនាខាងលើ ។

-ច ជាចំនួនអាសនៈថ្មីក្នុងខេត្ត ក្រុង ដោយពុំគិតចំនួនសល់ ។

**មាត្រា ១០ .-**

ចំពោះខេត្ត ក្រុងណាដែលមានប្រជាពលរដ្ឋតិចជាងផលចែកប្រភាគក៏ត្រូវមានអាសនៈមួយដែរ ។

ចំពោះអាសនៈដែលនៅសល់ គណៈកម្មការកំណត់អាសនៈរដ្ឋសភា អាចធ្វើសំណើបន្ថែមអាសនៈទៅខេត្ត ក្រុង ដោយផ្អែកតាមស្ថានភាពភូមិសាស្ត្រ សង្គមនិងសេដ្ឋកិច្ច។

## ជំពូកទី ៣

## ការគ្រប់គ្រងការបោះឆ្នោត

**មាត្រា ១១ .-**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវគ្រប់គ្រងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោះ ហៅកាត់ " គ.ជ.ប " ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ដើម្បីអនុវត្តការងាររបស់ខ្លួន ។

**មាត្រា ១២ .-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាអង្គការឯករាជ្យ និង អព្យាក្រឹតក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ។

សមាជិកទាំងឡាយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិក នៃគណៈ-ការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរអព្យាក្រឹត្យឥតលំអៀងក្នុងការអនុវត្តការងារបោះឆ្នោត ។

**មាត្រា ១៣ .-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាពដូចតទៅ :

-ឥស្សរជនខ្មែរ មួយរូប ប្រធាន

-ឥស្សរជនខ្មែរ មួយរូប អនុប្រធាន

-ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោត ពីររូប សមាជិក

-តំណាងមួយរូបនៃគណបក្សនយោបាយនីមួយៗ

ដែលមានអាសនៈក្នុងរដ្ឋសភា សមាជិក

-មន្ត្រីជាន់ខ្ពស់របស់ក្រសួងមហាផ្ទៃ ពីររូប សមាជិក

-តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិក្នុងស្រុក មួយរូប សមាជិក

ប្រធាននិងអនុប្រធាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានបទពិសោធន៍ខាងនយោបាយ និងបទពិសោធន៍ក្នុងការងារ ។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងតិចប្រាំបួន (៩)ខែ មុនថ្ងៃបោះឆ្នោតតាមសំណើរបស់គណៈរដ្ឋមន្ត្រី ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃសមាជិក រដ្ឋសភាទាំងមូល ។

ប្រធាន អនុប្រធាននិងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

ក្រសួងមហាផ្ទៃមានភារកិច្ចដាក់ជូនគណៈរដ្ឋមន្ត្រី នូវសេចក្តីព្រាងសមាសភាព នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយ៉ាងតិចដប់មួយ (១១) ខែ មុនថ្ងៃបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិជ្រើសរើសបុគ្គលិកតាមការចាំបាច់ សំរាប់ដំណើរការបោះឆ្នោត និងមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

**មាត្រា ១៤ .-**

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្មីអោយបានសំរេចយ៉ាងយូរហុកសិប (៦០) បន្ទាប់ពីថ្ងៃរំលាយរដ្ឋសភា ។

**មាត្រា ១៥ .-**

ប្រធាននិងអនុប្រធាន [illegible]កម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាសមាជិក នៃគណបក្សនយោបាយ ឬនិងជាមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំងក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសុំលាលែងពីគណបក្សនយោបាយជាស្ថាពរឬនិង ដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌរហូតដល់ថ្ងៃចប់អាណត្តិ ។ សមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិង ប្រធាន អនុប្រធាន និង សមាជិកនៃគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់ រៀបចំការបោះឆ្នោត

ដែលជាសមាជិក នៃគណៈបក្សនយោបាយឬនិងជាមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំងក្នុងគណៈកម្មាធិការជាតិ ឬ ក្នុងគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវសុំលាលែងពីគណបក្សនយោបាយជាបណ្តោះអាសន្ន ឬនិង ដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌ ដរាបហូតដល់ថ្ងៃចប់ភារកិច្ច ។

**មាត្រា ១៦ ..**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលខុសត្រូវធ្វើផែនការ រៀបចំនិងចាត់ចែងការបោះឆ្នោតក្នុងទូទាំងប្រទេស ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិពេញលេញក្នុងការអនុវត្តនីសមត្ថកិច្ចរបស់ខ្លួន។ សិទ្ធិអំណាចភារកិច្ច និងការទទួលខុសត្រូវទាក់ទងនឹងផែនការកម្មការរៀបចំការចាត់ចែងនិងការត្រួតពិនិត្យការបោះឆ្នោតមានដូចតទៅ :

១-ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាអោយការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ។

២-រៀបចំគំរោងផែនការការងារ ថវិកានិងសំភារៈបំរើអោយការបោះឆ្នោតផ្សព្វផ្សាយប្រតិទិន នៃការងារបោះឆ្នោត ។

៣-តែងតាំងគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណកម្មការ ឃុំ សង្កាត់ រៀបចំការបោះឆ្នោតនិងគណៈកម្មការការិយាល័យបោះឆ្នោត ។

៤-ធ្វើបទបញ្ញា នីតិវិធីនិងសេចក្តីណែនាំនានាសំរាប់ដំណើរការបោះឆ្នោតក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

៥-លើកវិធានការនិងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

៦-ត្រួតពិនិត្យការងាររបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៧-កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

៨-ចេញសេចក្តីសំរេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនិងការិយាល័យបោះឆ្នោត ។

៩-ផលិតនិងបែងចែកសំភារៈបរិក្ខារបំរើអោយការងារបោះឆ្នោត ។

១០-ជ្រើសរើសនិងតែងតាំងគណៈកម្មការចុះឈ្មោះបោះឆ្នោតតាមច្បាប់និងបទបញ្ជា។

១១-ធ្វើបញ្ជីបោះឆ្នោតនិងចេញប័ណ្ណបោះឆ្នោត ។

១២-ទទួល និង សំរេចលើពាក្យសុំឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ និង ការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្ររបស់គណបក្សនយោបាយ ។

១៣-ត្រួតពិនិត្យការប្រព្រឹត្តិទៅនៃការឃោសនាបោះឆ្នោត ។

១៤-រៀបចំនិងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការ ប្រកាសលទ្ធផល ។

១៥-ផ្តល់ប័ណ្ណបោះឆ្នោត ឬដកហូតប័ណ្ណបោះឆ្នោត ។

ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត របស់គណបក្សនយោបាយ ។

លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬ ទទួលស្គាល់ បេក្ខជនឈរឈ្មោះឡើងវិញ ។

១៦-ត្រួតពិនិត្យចំណូលនិងចំណាយ ក្នុងពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និង គណបក្សនយោបាយ ។

១៧-ចាត់វិធានការ ដើម្បីអោយមានការប្រើប្រាស់ប្រព័ន្ធឃោសនាសាធារណៈតាមគោល ការណ៍ស្មើភាព ។

១៨-ផ្តល់ពត៌មានអំពីដំណើរការបោះឆ្នោតដល់គណបក្សនយោបាយ និង បេក្ខជន និងទទួល សំណើនានាទាក់ទងនឹងការងារបោះឆ្នោត ។

១៩-ផលិតឯកសារផ្សព្វផ្សាយអំពីការងារបោះឆ្នោត ។

២០-លើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងដោយមធ្យោបាយផ្សេងៗទៀត ។

២១-រៀបចំឯកសារកម្មវិធីនិងបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត។

២២-ពិនិត្យសំរេច និង ចេញប័ណ្ណសំគាល់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ ជាតិនិងអន្តរជាតិ ។

២៣-ត្រួតពិនិត្យភាពត្រឹមត្រូវតាមច្បាប់ បទបញ្ញានិងតាមនីតិវិធីនៃការអនុវត្តន៏ការងារបោះឆ្នោះ ។

២៤-សំរេចលើបណ្តឹងតវ៉ាទាក់ទងនឹងការបោះឆ្នោត លើកលែងតែបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

២៥-បង្ការនិងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត ។

២៦-អនុវត្តការងារដទៃទៀតដែលច្បាប់ និងបញ្ញាអនុញ្ញាតឬតម្រូវអោយអនុវត្ត ។

**មាត្រា ១៧.-**

របៀបរបបធ្វើការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់ ដោយបទបញ្ញាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំបោះឆ្នោត ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ និងតាមបទបញ្ញា ។ រាល់ការសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចយកជាការបានលុះត្រាតែមានមតិភាគច្រើនដាច់ខាតយល់ព្រម ។

**មាត្រា ១៨.-**

សមាសភាពគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបានតែងតាំងដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងចំណោមប្រជាពលរដ្ឋមន្ត្រីរាជការនិងឬអ្នកមុខ អ្នកការក្នុងខេត្ត ក្រុង ដែលមានសិទ្ធិបោះឆ្នោត លើកលែងតែយោធិន នគរបាល មន្ត្រីតុលាការបុព្វជិតសាសនា និងអភិបាល អភិបាលរង ខេត្ត ក្រុង ។

សមាសភាពនៃគណៈកម្មការខេត្ត ក្រុងនេះ ត្រូវមានប្រធានមួយរូប អនុប្រធាន មួយរូប និងសមាជិកពីបីទៅប្រាំរូប ។ គណៈកម្មការខេត្ត ក្រុង នេះមានលេខាធិការដ្ឋានមួយជា ជំនួយការ ។

ក្នុងចន្លោះពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតត្រូវចាត់អោយមន្ត្រីលេខាធិការដ្ឋានមួយរូបឬពីររូប ដើម្បីបន្តនិរន្តភាពការងារបោះឆ្នោតនៅតាមខេត្ត ក្រុង ។

**មាត្រា ១៩.-**

ភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោតមានដូចតទៅ :

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ញានិងលិខិតបទដ្ឋាននានាអនុញ្ញាត ឬតម្រូវអោយអនុវត្ត ។

២-អនុវត្តភារកិច្ចនិងសិទ្ធិផ្សេងៗ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់អោយ ។

**មាត្រា ២០.-**

សមាសភាពគណៈកម្មការ ឃុំ សង្កាត់ រៀបចំការបោះឆ្នោតត្រូវបានតែងតាំងឡើង ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសំណើរបស់គណៈកម្មការ ខេត្ត ក្រុង រៀបចំការបោះឆ្នោតក្នុងចំណោមប្រជាពលរដ្ឋ មន្ត្រីរាជការនិងឬអ្នកមុខអ្នកការក្នុងស្រុក ខ័ណ្ឌ ឃុំ សង្កាត់ ដែលមានសិទ្ធិបោះឆ្នោត លើកលែងតែយោធិន នគរបាល មន្ត្រីតុលាការ បព្វជិតសាសនានិងមេឃុំ ជំទប់ចៅសង្កាត់ចៅសង្កាត់រង ។

សមាសភាពគណៈកម្មការនេះមានប្រធានមួយរូប អនុប្រធានមួយរូបនិងសមាជិក បីរូប ។

**មាត្រា ២១.-**

គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតមានភារកិច្ច និងការទទួលខុសត្រូវដូចតទៅៈ

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ញានិងលិខិតបទដ្ឋាននានា អនុញ្ញាត ឬតម្រូវអោយអនុវត្ត ។

២-អនុវត្តភារកិច្ចនិងសិទ្ធិផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់អោយ ។

**មាត្រា ២២.-**

សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបានតែងតាំងឡើងដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសំណើរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតក្នុងចំណោមប្រជាពលរដ្ឋ មន្ត្រីរាជការក្នុងស្រុក ខ័ណ្ឌ ឃុំ សង្កាត់ដែលមានសិទ្ធិបោះឆ្នោត លើកលែងតែយោធិន នគរបាល មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរង ស្រុក ខ័ណ្ឌ មន្ត្រីដែលបម្រើការរដ្ឋបាលក្នុងសាលាឃុំ សង្កាត់ និងប្រធានភូមិ ។

សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រធានមួយរូប អនុប្រធានមួយរូប លេខាធិការមួយរូបនិងសមាជិកពីពីររូបទៅបួនរូប តាមការចាំបាច់ និងតាមការកំណត់របស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៣.-**

ភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មការការិយាល័យបោះឆ្នោត មានដូចតទៅ :

១-អនុវត្តភារកិច្ចដែលច្បាប់ បញ្ញានិងលិខិតបទដ្ឋាននានាអនុញ្ញាតឬតម្រូវអោយអនុវត្ត ។

២-អនុវត្តភារកិច្ចនិងសិទ្ធិផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រគល់អោយ ។

**មាត្រា ២៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចចេញសេចក្ដីសំរេចប្រគល់សិទ្ធិរបស់ខ្លួនដល់គណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោតគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការការិយាល័យបោះឆ្នោត និង មន្ត្រីឬភ្នាក់ងារបម្រើការងារបោះឆ្នោត ដើម្បីអនុវត្តការងារបោះឆ្នោត ។

**មាត្រា ២៥.-**

បេក្ខជនឈរឈ្មោះបោះឆ្នោតជាតំណាងរាស្ត្រ ឬ សមាជិកគណៈកម្មាធិការនាយក នៃគណបក្សនយោបាយមិនអាចចូលជារូមក្នុងសមាសភាពគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតបានឡើយ ។

**មាត្រា ២៦.-**

គណបក្សនយោបាយនីមួយៗ ដែលឈរឈ្មោះបោះឆ្នោតអាចបញ្ជូនតំណាងរបស់ខ្លួនមួយនាក់ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតចូលរួមសង្កេតការណ៍មើលការបោះឆ្នោតតាម ការិយាល័យបោះឆ្នោតនីមួយៗ ។

**មាត្រា ២៧.-**

អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានា អាចបញ្ជូនតំណាងរបស់ខ្លួនអោយចូលរួមជាអ្នកសង្កេតការណ៍ការបោះឆ្នោត ។

**មាត្រា ២៨.-**

តំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ អង្គការអន្តរជាតិនិងប្រទេសនានាដែលចូលរួមសង្កេតការណ៍បោះឆ្នោតត្រូវមានការទទួលស្គាល់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៩.-**

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការឃោសនាបោះឆ្នោតការបោះឆ្នោតតាមសំណើរបស់គណៈកម្មាធិការជាតិ ឬ គណៈកម្មការរៀបចំការបោះឆ្នោត ។

**មាត្រា ៣០.-**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈ និង បុព្វសិទ្ធិស្មើនឹងឧបនាយករដ្ឋមន្ត្រី ។ អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈនិងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី ។ សមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ ។ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះ ឆ្នោតត្រូវមានឋានៈនិងបុព្វសិទ្ធិស្មើនឹងអគ្គនាយកក្រសួង ។

**មាត្រា ៣១.-**

សមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដទៃទៀត ព្រមទាំងបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន លេខាធិការដ្ឋាន ត្រូវបានទទួលប្រាក់កម្រៃតាមការកំណត់ របស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣២.-**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបំពេញការងាររបស់ខ្លួនរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាស្ថាពរ ។

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបំពេញការងាររបស់ខ្លួនរហូតដល់ហុកសិប (៦០) ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាស្ថាពរ ។ ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបន្តការងាររបស់ខ្លួនរហូតដល់មានការតែងតាំងថ្មី ។

## ជំពូកទី ៤

## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

**មាត្រា ៣៣.-**

ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម :

១-មានសញ្ជាតិខ្មែរពីកំណើត ។

២-មានអាយុម្ភៃប្រាំ (២៥) ឆ្នាំ ឡើងទៅគិតទៅដល់ថ្ងៃបោះឆ្នោត ។

៣-មានសិទ្ធិបោះឆ្នោត ។

៤-ស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិចមួយ (១) ឆ្នាំ គិតទៅដល់ថ្ងៃបោះឆ្នោត ។

៥-មានការតែងតាំងពីគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ។

**មាត្រា ៣៤.-**

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ :

១-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបព្វជិតសាសនា ឬ

២-ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

៣-ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬ

៤-ជនវិកលចរិតឬជនដែលស្ថិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

៥-ជនដែលត្រូវដកហូតប័ណ្ណបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ

៦-សមាជិកនៃគណៈកម្មាធិការជាតិ និង គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬ

៧-សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

៨-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៣៥.-**

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង បព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ ពិសេសឬលាចាកសិក្ខាបទ រហូតដល់ថ្ងៃប្រកាសលទ្ធផល នៃការបោះឆ្នោតជា ស្ថាពរយ៉ាងតិចប្រាំពីរ (៧) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត ។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួង ឬសាមីអង្គភាពទៅបំរើការក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងឋានៈនេះសាមីខ្លួនត្រូវនៅមានសិទ្ធិឡើងឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សា អតីតភាពការងារសំរាប់ទទួលសោធននិវត្តន៍ ។

នៅពេលចប់អាណត្តិជាតំណាងរាស្ត្រ សាមីខ្លួនអាចសុំត្រឡប់មកបំរើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសំរេច ។

**មាត្រា ៣៦.-**

បែបបទនៃការអនុវត្តមាត្រា ៣៣ មាត្រា ៣៤ នៃច្បាប់នេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធី ។

មាត្រា ៣៧.-

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើមមួយរយម្ភៃ (១២០)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាផ្លូវការ គណបក្សនយោបាយត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមបែបបទកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មកគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត យ៉ាងយូរកៅសិប (៩០)ថ្ងៃ មុនថ្ងៃបោះឆ្នោតដោយភ្ជាប់មកជាមួយ :

១-សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយច្បាប់ ។

២-ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និង សញ្ញាសំគាល់គណបក្សនយោបាយ ។

៣-អាស័យដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ ។

៤-បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបទូទាំងប្រទេស ។ បញ្ជីនេះត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិចមួយភាគបី (១/៣) នៃចំនួនអាសនៈក្នុងរដ្ឋសភានិងបេក្ខជន បម្រុងចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិ ។

៥-ឈ្មោះមណ្ឌលដែលគណបក្សនយោបាយមានបំណងទៅឈរ និងបញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលទាំងនោះ ។ បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលត្រូវមានចំនួនបេក្ខជន គ្រប់តាមចំនួនកំណត់អាសនៈ និង តាមគំរូដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្តល់អោយ ។

ចំពោះមណ្ឌលបោះឆ្នោតដែលមានអាសនៈមួយឬពីរ ត្រូវមានបេក្ខជនបម្រុងចំនួនយ៉ាងតិចបីរូប ។

៦-សេចក្តីប្រកាសអំពីគណនីធនាគារ ដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗ រួមមានទាំងវិភាគទាន ដែលបានមកពីប្រភពណាក៏ដោយនៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ។

៧-លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗ ដែលបញ្ជាក់ពីការបង្កើតគណបក្សនយោបាយ ។

៨-សេចក្តីប្រកាសរបស់គណបក្សនយោបាយ សន្យាថាចូលរួមបោះឆ្នោតដោយត្រឹមត្រូវ ដោយសេរី ទទួលយកលទ្ធផលនៃការបោះឆ្នោតនិងចូលរួមអនុវត្តច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្រមសីលធម៌និងច្បាប់ស្តីពីគណបក្សនយោបាយ ។

៩-បញ្ជីរាយនាមគណៈកម្មាធិការនាយកឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ ។

១០-បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួនដប់លាន (១០.០០០.០០០) រៀល ដែលចេញអោយដោយធនាគារជាតិ ។ ប្រាក់តម្កល់នេះត្រូវបានបង្វិលជូនទៅសាមីគណបក្សនយោបាយវិញក្នុងករណីដែលគណបក្សនយោបាយនោះ បានទទួលសន្លឹកឆ្នោតយ៉ាងតិចបីភាគរយ (៣%) នៃ ចំនួនសន្លឹកឆ្នោតបានការ ឬបានអាសនៈមួយក្នុងរដ្ឋសភា ។

ក្នុងករណី ដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិការចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវប្រព្រឹត្តទៅក្នុងរយៈពេលដប់(១០) ថ្ងៃ គិតពីថ្ងៃប្រកាសរំលាយរដ្ឋសភា ។

**មាត្រា ៣៨.-**

បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលត្រូវ :

១-ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ ។

២-ចុះលេខប័ណ្ណបោះឆ្នោតរបស់បេក្ខជនម្នាក់ៗ ។

៣-ភ្ជាប់សេចក្តីប្រកាសរបស់បេក្ខជនយល់ព្រមទទួលការ តែងតាំងជាបេក្ខជនតាមមណ្ឌលរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

**មាត្រា ៣៩.-**

បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះសំរាប់មណ្ឌលតែមួយគត់ ។

បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះលើសពីមួយមណ្ឌល ត្រូវបានប្រកាសថាបាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទោះ ជាសាមីខ្លួនទៅឈរឈ្មោះជាបេក្ខជនក្នុងគណបក្សនយោបាយណាផ្សេងទៀតក៏ដោយ ។

មាត្រា ៤០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យសំរេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវពិនិត្យនិងសំរេចលើពាក្យសុំចុះបញ្ជីគណៈបក្សនយោបាយឈរឈ្មោះបោះឆ្នោតជាបន្ទាន់ ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជូនសាមីគណបក្សនយោបាយ ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយនោះ ពុំបានបំពេញល័ក្ខខ័ណ្ឌណាមួយដែលមានចែងក្នុងមាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ និងមាត្រា ៣៨ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយនោះវិញ ដើម្បីបំពេញបន្ថែម ។

គណបក្សនយោបាយនេះ ត្រូវបំពេញល័ក្ខខ័ណ្ឌដែលខ្វះខាតយ៉ាងយូរដប់ (១០) ថ្ងៃ បន្ទាប់ពីថ្ងៃដែលសាមីគណបក្សនយោបាយបានទទួលលិខិតជូនដំណឹង ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ គណបក្សនយោបាយត្រូវបំពេញល័ក្ខខ័ណ្ឌដែលខ្វះខាតអោយទាន់មុនពេលបញ្ឈប់បញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

ផុតកំណត់នេះ បើគណបក្សនយោបាយពុំបានបំពេញល័ក្ខខ័ណ្ឌទាំងនោះទេ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចាត់ទុកថា គណបក្សនយោបាយនោះបោះបង់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

មាត្រា ៤១.-

ប្រសិនបើបេក្ខភាព ឬ បញ្ជីរាយនាមបេក្ខជនណាមួយត្រូវបានបដិសេធតាមបទប្បញ្ញត្តិ នៃមាត្រា ៣៣ ឬមាត្រ ៣៤ ឬមាត្រា ៣៥ ឬមាត្រា ៣៦ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

-បំពេញបែបបទនៃការបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លង នៃសេចក្តីបដិសេធមួយច្បាប់ទៅសាមីខ្លួននិងសាមីគណបក្សនយោបាយ ។

-ផ្តល់ពត៌មានដល់សាមីខ្លួន និងទៅសាមីគណបក្សនយោបាយថា អនុលោមតាមមាត្រា ៤២ នៃច្បាប់នេះ សាមីខ្លួនឬសាមីគណបក្សនយោបាយអាចប្តឹងតវ៉ាជាលាយលក្ខអក្សរ ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ សាមីខ្លួនឬសាមីគណបក្សនយោបាយអាចប្តឹងតវ៉ាជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់ ។

-ផ្ញើសេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាពត៌មាននិងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ៤២.-**

បេក្ខភាពណាដែលត្រូវបានបដិសេធ ឬបញ្ជីរាយនាមបេក្ខជនរបស់គណបក្សនយោបាយណាដែលត្រូវបានបដិសេធ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសាមីខ្លួន ឬសាមីគណបក្សនយោបាយនោះមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

ក្នុងករណី ដែលរដ្ឋសភាត្រូវបានរំលាយមុនអាណត្តិ សាមីខ្លួន ឬ សាមីគណបក្សនយោបាយអាចប្តឹងតវ៉ាជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យនិងសំរេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេលដប់ (១០) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសំរេចលើបណ្តឹងតវ៉ានេះជាបន្ទាន់ ។

**មាត្រា ៤៣.-**

សវនាការឬផ្នែកមួយ នៃសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលវិនិច្ឆ័យទៅលើបណ្តឹងតវ៉ាត្រូវធ្វើជាចំហ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបិទផ្សាយថ្ងៃ ខែ ឆ្នាំ ទីកន្លែងនិងពេលវេលា នៃការបើកសវនាការវិនិច្ឆ័យលើបណ្តឹងតវ៉ានេះ ។

**មាត្រា ៤៤.-**

បន្ទាប់ពីបានបញ្ចប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតឬនិងក្រោយពេល ដែលបណ្តឹងតវ៉ាត្រូវបានដោះស្រាយជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោតត្រូវបិទផ្សាយបញ្ជីរាយនាមគណៈបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនិងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាម ខេត្ត ក្រុង របស់គណបក្សនយោបាយទាំងនោះទៅតាមការកំណត់ដូចមានចែងក្នុងបទបញ្ជា និងនីតិវិធី ។

## ជំពូកទី ៥

## ការិយាល័យបោះឆ្នោត

**មាត្រា ៤៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសំរេចបង្កើតការិយាល័យចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ដូចមានចែងក្នុងបទបញ្ជានិងនីតិវិធី ។

ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវទៅជាការិយាល័យបោះឆ្នោតនៅពេលបោះឆ្នោតលើកលែងតែការិយាល័យចល័តចុះឈ្មោះបោះឆ្នោត ។

**មាត្រា ៤៦.-**

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតយ៉ាងច្រើនប្រាំមួយរយ(៦០០)នាក់ លើកលែងតែមានសេចក្តីសំរេចផ្សេងអំពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវប្រមូលផ្តុំដោយភូមិទាំងមូលនិងត្រូវបង្កលក្ខណៈអោយសមាជិកទាំងអស់របស់គ្រួសារក្នុងភូមិនោះ បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត និង បានទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

**មាត្រា ៤៧.-**

ឈ្មោះនិងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ដែលបានកំណត់ហើយត្រូវបិទផ្សាយជាសាធារណៈ ។

គណៈបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតអាចសុំតារាងកំណត់ឈ្មោះ និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនេះបានដោយបង់ថ្លៃ ។

តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ជូនតារាងឈ្មោះនិងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៃមណ្ឌលនីមួយៗមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី៦

### ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត

**មាត្រា ៤៨.-**

បញ្ជីបោះឆ្នោតនៃការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវបានរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ បញ្ជីបោះឆ្នោតនៃការិយាល័យចុះឈ្មោះបោះឆ្នោតទាំងអស់នេះត្រូវកត់ចូលក្នុងសៀវភៅបញ្ជីមួយ ហើយរក្សាទុកជាឯកសារនៅទីស្នាក់ការគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការកៅសិប (៩០) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ បញ្ជីបោះឆ្នោតត្រូវយកបញ្ជីបោះឆ្នោតចុងក្រោយទុកជាផ្លូវការ ហើយត្រូវផ្សព្វផ្សាយបញ្ជីនេះយ៉ាងតិចហាសិប(៥០) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

**មាត្រា ៤៩.-**

សៀវភៅបញ្ជីនេះត្រូវរក្សាទុកជាអចិន្ត្រៃយ៍ ។ រយៈពេលចុះឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានកំណត់ដោយការប្រកាសជាសាធារណៈ ។ រយៈពេលចុះឈ្មោះនេះអាចកែប្រែបានដោយការប្រកាសជាសាធារណៈ ផ្អែកតាមសភាពការណ៍នៃប្រទេសជាតិ ឬ សភាពការណ៍នៃខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ឬការិយាល័យចុះឈ្មោះបោះឆ្នោត ។

**មាត្រា ៥០.-**

ដើម្បីបោះឆ្នោត ប្រជាពលរដ្ឋទាំងឡាយត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនិងមានប័ណ្ណបោះឆ្នោត ។

លក្ខខ័ណ្ឌ នៃការចុះឈ្មោះបោះឆ្នោតគឺ :

១-មានសញ្ជាតិខ្មែរ ។

២-មានអាយុ ១៨ឆ្នាំ ឡើងទៅគិតទៅដល់ថ្ងៃបោះឆ្នោត ។

៣-មានអាស័យដ្ឋានច្បាស់លាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤-ត្រូវទៅចុះឈ្មោះដោយខ្លួនឯងផ្ទាល់ ។

៥-មិនត្រូវស្ថិតនៅក្នុងស្ថានភាពជាប់ពន្ធនាគារ ។

៦-ពុំមែនជាជនវិកលចរិត ឬ ជនដែលស្ថិតក្រោមអាណាព្យាបាលដែលមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ៥១.-**

បេក្ខជនដែលឈរឈ្មោះបោះឆ្នោត សហព័ទ្ធនិងកូនអាចទៅចុះឈ្មោះបោះឆ្នោតនៅមណ្ឌលបោះឆ្នោតដែលខ្លួនឈរឈ្មោះបោះឆ្នោតតាមលក្ខខ័ណ្ឌនៃមាត្រា ៥០ នៃច្បាប់នេះ ។

**មាត្រា ៥២.-**

ប្រជាពលរដ្ឋខ្មែរម្នាក់ៗ ត្រូវមានឈ្មោះតែមួយនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់ ។

**មាត្រា ៥៣.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតែងតាំងភ្នាក់ងារអោយចុះឈ្មោះបោះឆ្នោត ឬពិនិត្យបញ្ជីបោះឆ្នោតសាឡើងវិញនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតនានា ។

**មាត្រា ៥៤.-**

ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋម្នាក់ៗត្រូវទៅបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត ដោយបង្ហាញឯកសារដូចមានកំណត់ក្នុងបទបញ្ជានិងនីតិវិធី ។

ប្រសិនបើប្រជាពលរដ្ឋមានឯកសារគ្រប់គ្រាន់ត្រឹមត្រូវហើយ ភ្នាក់ងារចុះឈ្មោះបោះឆ្នោត តាមការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវ:

-ចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត ។

-កត់ឈ្មោះប្រជាពលរដ្ឋនោះចូលក្នុងសៀវភៅបញ្ជីអ្នកបោះឆ្នោត ។

-ចេញប័ណ្ណបោះឆ្នោតជូនសាមីខ្លួន ។

ចំពោះប្រជាពលរដ្ឋណា ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតពីមុនកន្លងមកហើយភ្នាក់ងារ ចុះឈ្មោះបោះឆ្នោតគ្រាន់តែពិនិត្យភស្តុតាង នៃការចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតពីមុនរួច អនុវត្តការ ចុះឈ្មោះបោះឆ្នោតតាមលក្ខណការណ៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី២នៃមាត្រានេះ។

**មាត្រា ៥៥.-**

ហាមឃាត់មិនអោយយកអាវុធ ឬជាតិផ្ទុះចូលក្នុងបរិវេណការពារសន្តិសុខ នៃ ការិយាល័យ ចុះឈ្មោះបោះឆ្នោត ។

**មាត្រា ៥៦.-**

ភ្នាក់ងារចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោត អាចបដិសេធការចុះ ឈ្មោះដល់អ្នកមកចុះឈ្មោះ ក្នុងករណីដែលមានភស្តុតាងបញ្ជាក់ថា ជននោះពុំមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ តាមមាត្រា ៥០ និងមាត្រា ៥១ នៃច្បាប់នេះ ។

ក្នុងករណីដែលភ្នាក់ងារចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោត បដិសេធ ការចុះឈ្មោះបោះឆ្នោតរបស់ប្រជាពលរដ្ឋ ភ្នាក់ងារចុះឈ្មោះបោះឆ្នោតត្រូវ :

-បំពេញបែបបទនៃការបដិសេធដោយបញ្ជាក់ពីមូលហេតុនិងកាលបរិច្ឆេទនៃការ បដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធមួយច្បាប់ជូនសាមីខ្លួន ។

-ផ្តល់ពត៌មានដល់សាមីខ្លួនថា អនុលោមតាមមាត្រា៥៧ នៃច្បាប់នេះសាមីខ្លួន ឬ អ្នកដទៃ ទៀតអាចប្តឹងតវ៉ាទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសំណុំឯកសារបដិសេធមួយច្បាប់ទៅគណៈកម្មការ ខេត្ត ក្រុង រៀបចំការបោះឆ្នោត ដើម្បីជាពត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ៥៧.-**

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួនត្រូវបានបដិសេធ ដោយភ្នាក់ងារចុះឈ្មោះតាមការិយាល័យចុះឈ្មោះបោះឆ្នោត ជននោះឬអ្នកដទៃទៀតអាចប្តឹងតវ៉ាជាលាយលក្ខអក្សរទៅគណៈកម្មការ ខេត្ត ក្រុងរៀបចំការបោះឆ្នោតក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

**មាត្រា ៥៨.-**

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវសំរេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

សាធារណជនអាចចូលរួមស្តាប់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតសំរេចលើបណ្តឹងតវ៉ានេះបាន ។

**មាត្រា ៥៩.-**

ប្រសិនបើគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចាត់អោយភ្នាក់ងារចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោត អនុវត្តការចុះឈ្មោះតាមលក្ខណការណ៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ៥៤ នៃច្បាប់នេះ ។

ប្រសិនបើគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពុំយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ាគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវ :

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុនិងកាលបរិច្ឆេទ នៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធមួយច្បាប់ជូនសាមីខ្លួន ។

-ផ្តល់ពត៌មានជូនសាមីខ្លួនថា អនុលោមតាមមាត្រា ៦០ នៃច្បាប់នេះសាមីខ្លួន ឬ អ្នកដទៃទៀតអាចប្តឹងតវ៉ា ជាលាយលក្ខអក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសំណុំឯកសារបដិសេធមួយច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីជាពត៌មាននិងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ៦០.-**

ជនណាដែលបណ្តឹងតវ៉ារបស់ខ្លួន ត្រូវបានបដិសេធដោយគណៈកម្មការ ខេត្ត ក្រុង រៀបចំការបោះឆ្នោត ជននោះឬអ្នកដទៃទៀតអាចប្តឹងតវ៉ាជាលាយលក្ខអក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

**មាត្រា ៦១.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសំរេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេល ប្រាំពីរ (៧) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញសេចក្តីសំរេចទៅគណៈកម្មការ ខេត្ត ក្រុង រៀបចំការបោះឆ្នោត ដើម្បីចាត់អោយភ្នាក់ងារចុះឈ្មោះតាមការិយាល័យចុះឈ្មោះបោះឆ្នោតចុះឈ្មោះអ្នកដែលត្រូវបានបដិសេធ ដោយអនុវត្តតាមលក្ខណការណ៍ចុះឈ្មោះបោះ ឆ្នោតដូចមានចែងក្នុងវាក្យខណ្ឌទី ២ មាត្រា ៥៤ នៃច្បាប់នេះ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពុំយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុនិងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធនេះមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ។

-ផ្តល់ពត៌មានទៅសាមីខ្លួនថា អនុលោមតាមមាត្រា ៦២ នៃច្បាប់នេះសាមីខ្លួន ឬ អ្នកដទៃទៀតអាចប្តឹងតវ៉ាជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសេចក្តីចម្លងនៃការបដិសេធនេះមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាពត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

មាត្រា ៦២.-

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួនត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ជននោះឬអ្នកដទៃទៀតអាចប្តឹងតវ៉ាជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសំរេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេលដប់ (១០) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមឬមិនយល់ព្រមតាមបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ :

-ចេញសេចក្តីសំរេចអោយគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតចុះឈ្មោះ ឬ បដិសេធឈ្មោះអ្នកប្តឹងតវ៉ា ។

-ផ្ញើសេចក្តីចម្លងនៃសេចក្តីសំរេចយល់ព្រមឬបដិសេធនេះមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ។

ប្រសិនបើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញតម្រូវអោយចុះឈ្មោះអ្នកប្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់អោយភ្នាក់ងារចុះឈ្មោះបោះឆ្នោត ចុះឈ្មោះបោះឆ្នោតអ្នកដែលមានបញ្ហានោះតាមលក្ខណការណ៍ចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងវាក្យ ខ័ណ្ឌទី ២ មាត្រា ៥៤ នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មីនៃការិយាល័យចុះឈ្មោះ បោះឆ្នោតដែលពាក់ព័ន្ធនោះមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ៦៣.-

បន្ទាប់ពីថ្ងៃបញ្ចប់ការចុះបញ្ជីបោះឆ្នោតភ្លាម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់អោយបិទផ្សាយបញ្ជីបោះឆ្នោតដំបូង នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត តាមទីស្នាក់ការឃុំ សង្កាត់រៀបចំការបោះឆ្នោតនិងនៅតាមទីស្នាក់ការគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត ។

គណបក្សនយោបាយ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតមានសិទ្ធិសុំបញ្ជីបោះឆ្នោតថតចម្លងនេះបានដោយបង់ថ្លៃ ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

**មាត្រា ៦៤.-**

ក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូងជនណាក៏ដោយក៏អាចប្តឹងតវ៉ាជាលាយលក្ខអក្សរទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពីការបាត់ឈ្មោះឬជំទាស់ការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃ ជនណាម្នាក់ដែលខ្លួនមានភស្តុតាងបញ្ជាក់ថា:

-ជននោះពុំមានល័ក្ខខ័ណ្ឌត្រឹមត្រូវ គ្រប់គ្រាន់តាមមាត្រា ៥០ នៃច្បាប់នេះ ។

-ជននោះបានចុះឈ្មោះបោះឆ្នោតចំនួនពីរ ឬច្រើនកន្លែង ។

-ជននោះកំពុងស្ថិតនៅក្នុងភាពរង់ចាំការសំរេចចុះឈ្មោះពីគណៈកម្មការ ខេត្ត ក្រុង រៀបចំការបោះឆ្នោត ឬពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឬពីក្រុមប្រឹក្សាធម្មនុញ្ញតែសាមីខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬមានប័ណ្ណបោះឆ្នោតរួចហើយ ។

**មាត្រា ៦៥.-**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវសំរេចលើបណ្តឹងតវ៉ា ឬជំទាស់ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ាឬជំទាស់នេះជាការត្រឹមត្រូវ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចាត់អោយចុះឈ្មោះសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត ដោយអនុលោមតាម លក្ខណការណ៍ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ៥៤ នៃច្បាប់នេះឬត្រូវលុបឈ្មោះអ្នក ដែលមានបញ្ហានោះចេញពីបញ្ជីបោះនិងពីសៀវភៅបញ្ជីអ្នកបោះឆ្នោតឬនិងដកហូតប័ណ្ណបោះ ឆ្នោតពីសាមីខ្លួន ។

ប្រសិនបើអ្នកតវ៉ាឬជំទាស់ឬអ្នកដែលមានបញ្ហាពុំពេញចិត្តនឹងការសំរេចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ជននោះឬអ្នកតំណាងអាចប្តឹងតវ៉ាជាលាយលក្ខអក្សរ ទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរបន្ទាប់ពី ថ្ងៃទទួលលិខិតជូនដំណឹងពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវសំរេចលើបណ្តឹងតវ៉ាឬជំទាស់នោះក្នុងរយៈពេលដប់ (១០) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើបណ្ដឹងតវ៉ា ឬជំទាស់នោះជាការត្រឹមត្រូវគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចាត់ការអោយភ្ជាក់ងារចុះឈ្មោះបោះឆ្នោត ចុះឈ្មោះអ្នកដែលមានបញ្ហានោះក្នុងបញ្ជីបោះឆ្នោត តាមលក្ខណការណ៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី២ មាត្រា ៥៤ នៃច្បាប់ នេះឬលុបឈ្មោះអ្នកដែលមានបញ្ហានោះ ចេញពីបញ្ជីបោះឆ្នោតនិងសៀវភៅបញ្ជីអ្នកបោះឆ្នោត ឬនិងដកហូតប័ណ្ណបោះឆ្នោតពីសាមីខ្លួន ។

ប្រសិនបើអ្នកតវ៉ា ឬ អ្នកជំទាស់ពុំពេញចិត្តនឹងការសំរេចរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ជននោះឬអ្នកតំណាងអាចប្ដឹងតវ៉ាជាលាយលក្ខអក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសំរេចលើបណ្ដឹងតវ៉ាឬជំទាស់នោះ ក្នុងរយៈពេលដប់ (១០) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

ប្រសិនបើបណ្ដឹងតវ៉ាឬជំទាស់នោះជាការត្រឹមត្រូវ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ការអោយភ្ជាក់ងារចុះឈ្មោះបោះឆ្នោត ចុះឈ្មោះអ្នកដែលមានបញ្ហានោះ ក្នុងបញ្ជីបោះឆ្នោតតាមលក្ខណការណ៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី២ មាត្រា ៥៤ នៃច្បាប់នេះ ឬលុបឈ្មោះអ្នកដែលមានបញ្ហានោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីអ្នកបោះឆ្នោតនិង ដកហូតប័ណ្ណបោះឆ្នោតពីសាមីខ្លួន ។

**មាត្រា ៦៦.-** [illegible]

ប្រសិនបើអ្នកប្ដឹងតវ៉ាឬជំទាស់នៅពុំពេញចិត្តនឹងការសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះឬអ្នកតំណាងអាចប្ដឹងតវ៉ាឬជំទាស់ជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចលើបណ្ដឹងតវ៉ាឬជំទាស់នោះ ក្នុងរយៈពេលដប់ (១០) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

ប្រសិនបើបណ្ដឹងតវ៉ាឬជំទាស់នោះជាការត្រឹមត្រូវ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ :

-ចេញសេចក្តីសំរេចអោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះ ឬ បដិសេធឈ្មោះអ្នកប្តឹងតវ៉ាឬអ្នកដែលមានបញ្ហា ។

-ផ្ញើសេចក្តីចម្លងនៃសេចក្តីយល់ព្រមឬបដិសេធនេះមួយច្បាប់ ទៅអ្នកប្តឹងតវ៉ា ឬអ្នកជំទាស់ ឬអ្នកជំទាស់ ឬអ្នកដែលមានបញ្ហា ។

ប្រសិនបើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញតម្រូវអោយចុះឈ្មោះអ្នកប្តឹងតវ៉ា ឬអ្នកដែលមានបញ្ហា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ការអោយភ្នាក់ងារ ចុះឈ្មោះតាមការិយាល័យចុះឈ្មោះបោះឆ្នោត ចុះឈ្មោះសាមីខ្លួនតាមលក្ខណការណ៍ចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ៥៤ នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែ ប្រែថ្មីនៃការិយាល័យចុះឈ្មោះបោះឆ្នោតដែលពាក់ព័ន្ធនោះមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៦៧.-**

នៅពេលដែលបណ្តឹងតវ៉ាត្រូវបានសំរេចជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការនៅការិយាល័យចុះឈ្មោះបោះឆ្នោត នៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតនិងនៅទីស្នាក់ការគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត ។

គណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតមានសិទ្ធិសុំបញ្ជីបោះឆ្នោតថតចម្លងបានដោយបង់ថ្លៃ ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

**មាត្រា ៦៨.-**

ជនណាដែលមានប័ណ្ណបោះឆ្នោតជារបស់បុគ្គលដែលស្លាប់ទៅ ត្រូវយកប័ណ្ណនោះមកប្រគល់ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតជាបន្ទាន់ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចាត់វិធានការ ដើម្បីលុបឈ្មោះអ្នកបោះឆ្នោតដែលស្លាប់នោះចេញពីបញ្ជីបោះឆ្នោតនិងពីរ សៀវភៅបញ្ជីអ្នកបោះឆ្នោត ហើយបញ្ជូនប័ណ្ណបោះឆ្នោតនោះទៅថ្នាក់លើដើម្បីបំផ្លាញចោល ។

មាត្រា ៦៩

...គណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាលជាតិនិងបរទេស អង្គការអន្តរជាតិនិងប្រទេសនានា អាចបញ្ជូនតំណាងរបស់ខ្លួនចូលសង្កេតការណ៍ក្នុងការិយាល័យចុះឈ្មោះបោះ ឆ្នោតបាន ។

តំណាងទាំងអស់ត្រូវមានការទទួលស្គាល់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៧

### ការឃោសនាបោះឆ្នោត

**មាត្រា ៧០.-**

ការឃោសនាបោះឆ្នោតមានទិសដៅអោយគណបក្សនយោបាយ និង បេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។

**មាត្រា ៧១.-**

គណបក្សនយោបាយនិងបេក្ខជនទាំងអស់ ត្រូវជៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយឬបេក្ខជនដទៃទៀត ។

គ្រប់គណបក្សនយោបាយនិងបេក្ខជនទាំងអស់មិនត្រូវញុះញង់អ្នកគាំទ្រ ឬ អ្នកបោះឆ្នោតអោយប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សាឬបំភិតអំភ័យទៅលើបុគ្គលឬគណបក្សនយោបាយដទៃឡើយ ។

**មាត្រា ៧២.-**

យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេលសាមសិប (៣០)ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោតត្រូវចប់ ២៤ម៉ោង មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៧៣.-**

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ត្រូវគោរពតាមវិធានបទប្បញ្ញត្តិនិងគោលការណ៍ ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ក្រមសីលធម៌ បទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧៤.-**

គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមមានសារព័ត៌មាន វិទ្យុនិងទូរទស្សន៍របស់រដ្ឋត្រូវទទួលចុះផ្សាយគ្រប់ព័ត៌មានដែលស្នើដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយមិនយកថ្លៃ ដើម្បីផ្សព្វផ្សាយពីការងារបោះឆ្នោត និងអប់រំដល់អ្នកបោះឆ្នោត ។

**មាត្រា ៧៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់វិធានការ ដើម្បីផ្សព្វផ្សាយអត្ថបទឃោសនាតាមសំណើរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតផ្អែក តាមគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយ ។

**មាត្រា ៧៦.-**

ក្នុងការអនុវត្តន៍សិទ្ធិផ្សព្វផ្សាយ គណបក្សនយោបាយនិងបេក្ខជនទាំងអស់មិនត្រូវប្រើអំពើហិង្សា អំពើរំលោភសំដីប្រមាថមើលងាយ មិនត្រូវសាបព្រួសអោយមានការភ័យខ្លាចការភាន់ច្រឡំធ្វើអោយច្របូកច្របល់បាត់ទុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

**មាត្រា ៧៧.-**

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជនឬគណបក្សនយោបាយ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់សម្រាប់បម្រើការឃោសនាដោយផ្អែកលើគោលការណ៍ស្មើភាពនិងតាមលំដាប់មុនក្រោយ ។

**មាត្រា ៧៨.-**

ក្នុងសម័យឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណបក្សនយោបាយ ឬ បេក្ខជនដែលមានបំណងជួលរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ដូចមានចែងក្នុងមាត្រា ៧៧ នៃច្បាប់នេះ ត្រូវធ្វើពាក្យសុំទៅអ្នកគ្រប់គ្រងទីកន្លែងទាំងនោះបី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃប្រជុំឃោសនា ហើយត្រូវចម្លងពាក្យសុំនេះមួយច្បាប់ផ្ញើទៅ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

អ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ត្រូវឆ្លើយតបនឹងពាក្យសុំជួលក្នុងរយៈពេលម្ភៃបួន (២៤) ម៉ោងយ៉ាងយូរបន្ទាប់ពីបានទទួលពាក្យសុំ ។

**មាត្រា ៧៩.-**

គណៈបក្សនយោបាយឬបេក្ខជនអាចធ្វើសកម្មភាពឃោសនានៅលើទីធ្លាឯកជន ឬ នៅសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងដល់ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

**មាត្រា ៨០.-**

គណបក្សនយោបាយ និង បេក្ខជនទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើអោយរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

**មាត្រា ៨១.-**

ចំណាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយ និង របស់បេក្ខជនម្នាក់ៗ ជាបន្ទុករបស់គណបក្សនយោបាយ ឬបេក្ខជនផ្ទាល់ ។

**មាត្រា ៨២.-**

គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនីដើម្បីកត់ប្រាក់ចំណូល ប្រភពនៃប្រាក់ចំណូលនិងចំណាយសម្រាប់ការឃោសនា បោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចត្រួតពិនិត្យសៀវភៅគណនីនេះ នៅពេលមានការចាំបាច់ ។

**មាត្រា ៨៣.-**

វិភាគទានទាំងអស់ដែលគណបក្សនយោបាយបានទទួល ត្រូវបញ្ចូលក្នុងគណនី នៃ ធនាគារ ហើយរាល់ចំណាយទៅលើការឃោសនាត្រូវតែចេញពីគណនីតែមួយនេះ ។

## ជំពូកទី ៨

### ការបោះឆ្នោត ការរាប់សន្លឹកឆ្នោតនិងការប្រកាសលទ្ធផលនៃការបោះឆ្នោត

**មាត្រា ៨៤.-**

ការិយាល័យបោះឆ្នោតត្រូវបានរៀបចំតាមការកំណត់ដូចមានចែងក្នុងមាត្រា៤៥នៃច្បាប់នេះ ។

**មាត្រា ៨៥.-**

ការបោះឆ្នោតត្រូវធ្វើតែមួយថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោងប្រាំពីរព្រឹក រហូតដល់ម៉ោងដប់ប្រាំមួយលើកលែងតែមានសេចក្តីសំរេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោតអាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោងដប់ប្រាំមួយ ។

**មាត្រា ៨៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយបញ្ជីឈ្មោះ និង ទាំងការិយាល័យបោះឆ្នោតហើយត្រូវបិទផ្សាយបញ្ជីទាំងនេះនៅគ្រប់ការិយាល័យបោះឆ្នោតសាមសិប (៣០) ថ្ងៃយ៉ាងតិចមុនថ្ងៃបោះឆ្នោត ។

**មាត្រា ៨៧.-**

គណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតអាចសុំសេចក្តីចម្លង នៃបញ្ជីឈ្មោះនិងទីតាំងការិយាល័យបោះឆ្នោតនេះបានដោយបង់ថ្លៃ ។ តម្លៃនេះគិតត្រឹមតែតម្លៃ ផលិតប៉ុណ្ណោះ ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់ជូនការិយាល័យបោះឆ្នោតនីមួយៗ នូវសម្ភារៈដូចតទៅ តាមចំនួនសមស្របមួយថ្ងៃមុនថ្ងៃបោះឆ្នោត :

១-បញ្ជីបោះឆ្នោត ។

២-សន្លឹកឆ្នោត ។

៣-ហិបឆ្នោត ។

៤-បន្ទប់សម្ងាត់ ។

៥-ទឹកជ្រលក់ដៃ ។

៦-សោនិងប្រដាប់ឃ្នុំ ។

៧-ក្រដាសបែបបទសំរាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល ។

៨-ប៊ិចសរសេរ ។

៩-ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ ។

១០-ថង់ប្លាស្ទិក ។

១១-សំភារៈនិងបរិក្ខារចាំបាច់ផ្សេងៗទៀត ។

មាត្រា ៨៩.-

មុនថ្ងៃបោះឆ្នោតមួយថ្ងៃ ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវប្រជុំសមាជិកទាំងអស់ដើម្បីត្រួតពិនិត្យវត្តមានសមាជិក និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និង ពិនិត្យសំភារៈបរិក្ខារបម្រើអោយការងារបោះឆ្នោត ។

ប្រសិនបើមានសមាជិកណាម្នាក់អវត្តមាន សមាជិកនោះត្រូវតែជំនួសដោយសមាជិកថ្មី ដែលជ្រើសតាំងឡើងស្របតាមបទប្បញ្ញត្តិដែលចែងក្នុងបទបញ្ជានិងនីតិវិធី ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ការ ដើម្បីអោយការិយាល័យបោះឆ្នោតមានសម្ភារៈបរិក្ខារនិងសម្ភារីមចាំបាច់ សម្រាប់ការបោះឆ្នោត ។

ប្រធានគណៈកម្មការិយាល័យបោះឆ្នោតពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោតហើយចាត់វិធានការការពារសន្តិសុខប្រសិនបើចាំបាច់ ។

មាត្រា ៩០.-

នៅថ្ងៃបោះឆ្នោត សមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវមកដល់ទីតាំងការិយាល័យបោះឆ្នោត ដើម្បីរៀបចំការបោះឆ្នោតមួយម៉ោងយ៉ាងតិច មុនចាប់ផ្តើមការបោះឆ្នោត ។

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវគោរពតាមការណែនាំដែលចែងក្នុងបទបញ្ជា និងនីតិវិធី ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃតំណាងគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ មុននឹងអនុញ្ញាតអោយអ្នកទាំងនេះចូលក្នុងការិយាល័យបោះឆ្នោត ។

មាត្រា ៩១.-

មុននឹងចាប់ផ្តើមការបោះឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបើកបង្ហាញហិបឆ្នោតនៅចំពោះសមាជិកគណៈកម្មការ តំណាងគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ទាំងអស់ថា គ្មានអ្វីនៅក្នុងហិបឆ្នោតទេ រួចចាក់សោដែលមានឃ្លុំ ។ លេខឃ្លុំដែលចាក់នេះត្រូវចុះក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

**មាត្រា ៩២.-**

ប្រជាពលរដ្ឋម្នាក់ៗត្រូវបោះឆ្នោតតែនៅការិយាល័យបោះឆ្នោតដែលឈ្មោះរបស់ខ្លួនមាននៅក្នុងបញ្ជីបោះឆ្នោត និង ត្រូវមានប័ណ្ណបោះឆ្នោត លើកលែងតែមានបទបញ្ជាផ្សេងអំពីនេះ ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩៣.-**

សមាជិកនៃគណៈកម្មការការិយាល័យបោះឆ្នោតត្រូវបាននិមន្ត/អញ្ជើញអោយបោះឆ្នោត មុនគេ បន្ទាប់មកតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិដែលមានឈ្មោះ ក្នុង បញ្ជីបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតនោះ ។

**មាត្រា ៩៤.-**

អ្នកបោះឆ្នោតម្នាក់ៗ មានសិទ្ធិបោះឆ្នោតតែមួយសន្លឹកនិងតែមួយដងគត់ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ។

អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបោះអោយគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្តដោយគូសសញ្ញាយកតែគណបក្សនយោបាយមួយនិងមិនត្រូវកែ ដូរឬបន្ថែមបន្ថយទេ ។ របៀបបោះឆ្នោតលំអិតផ្សេងទៀតត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩៥.-**

ការបោះឆ្នោតជាការសម្ងាត់របស់អ្នកបោះឆ្នោត ។

ការចង់ដឹងអំពីការសម្ងាត់ ឬការបង្ខើបការសម្ងាត់តាមរូបភាពណាក៏ដោយត្រូវហាមឃាត់ ។

**មាត្រា ៩៦.-**

ដើម្បីរក្សារបៀបរៀបរយក្នុងបន្ទប់បោះឆ្នោត ជនម្នាក់ៗត្រូវគោរពតាមបទបញ្ជានៃការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩៧.-**

ចំពោះប្រជាពលរដ្ឋពិការដែលពុំអាចបោះឆ្នោតដោយខ្លួនឯងបាន ហើយត្រូវការជំនួយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់តាំងសមាជិកគណៈកម្មការការិយាកាល័យបោះឆ្នោតមួយនាក់អោយជួយ ។

មាត្រា ៩៨.-

ប្រជាពលរដ្ឋដែលមានប័ណ្ណបោះឆ្នោត តែពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ពុំអាចបោះឆ្នោតបានឡើយ ។

មាត្រា ៩៩.-

អាចចូលបានក្នុងការិយាល័យបោះឆ្នោតតែអ្នកត្រូវបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១០០.-

ហាមដាច់ខាតមិនអោយយកអាវុធឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោតនិងហាមមិនអោយស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពិសេសពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ទីធ្លាការិយាល័យបោះឆ្នោតត្រូវមានទំហំប្រមាណ ២០០០ម៉ែត្រការ៉េ ហើយរង្វង់ការពារសន្តិសុខត្រូវស្ថិតនៅចំងាយប្រមាណ ២០០ម៉ែត្រ ជុំវិញការិយាល័យបោះឆ្នោត លើកលែងតែមានការសំរេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១០១.-

ក្នុងករណីដែលតំណាងគណបក្សនយោបាយយល់ឃើញថា ការបោះឆ្នោតមិនប្រក្រតីតំណាងគណបក្សនយោបាយនោះ អាចប្តឹងជំទាស់ឬតវ៉ាមកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតបាន ។

របៀបបែបបទប្តឹងជំទាស់ឬតវ៉ា ត្រូវកំណត់ដោយបទបញ្ជានិងនីតិវិធី ។

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវដោះស្រាយបណ្តឹងជំទាស់ ឬតវ៉ានេះ ។

ការសំរេចរបស់គណៈកម្មការការិយាល័យបោះឆ្នោតជាការសំរេចបានការក្នុងកំរិតសមត្ថកិច្ច របស់ខ្លួន ប្រសិនបើការបោះឆ្នោតនោះប្រព្រឹត្តទៅដោយប្រក្រតី ។

ប្រសិនបើអ្នកតំណាងនោះនៅតែជំទាស់ឬតវ៉ា គណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះបណ្តឹងជំទាស់ឬតវ៉ានេះក្នុងកំណត់ហេតុ ដោយអោយអ្នកជំទាស់ឬតវ៉ានោះចុះហត្ថលេខាជាមួយ ។

**មាត្រា ១០២.-**

ក្រោយពីការប្រកាសបញ្ចប់ការបោះឆ្នោត គណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះក្នុងកំណត់ហេតុនូវចំនួនអ្នកដែលបានមកបោះឆ្នោត និង ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើប្រាស់ ហើយត្រូវរៀបចំដើម្បីរាប់សន្លឹកឆ្នោតនៅនឹងកន្លែងស្របតាមបទបញ្ជានិងនីតិវិធី ។

ចំពោះការិយាល័យបោះឆ្នោតណា ដែលមិនអាចរៀបចំរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបានដោយករណីប្រធានសក្តិ ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនឹងធ្វើការណែនាំដោយឡែក ។

អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិព្រមទាំងអ្នកតំណាងគណបក្សនយោបាយនីមួយៗ អាចចូលរួមជាសាក្សីក្នុងការរាប់សន្លឹកឆ្នោតនេះ ។

**មាត្រា ១០៣.-**

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវទទួលខុសត្រូវរាប់សន្លឹកឆ្នោត ។ មុននឹងបើកហិបឆ្នោតប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវអញ្ជើញសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត តំណាងគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ពិនិត្យ ឃ្លាំមើល ហើយបើកហិបឆ្នោតនៅចំពោះមុខអ្នកទាំងនោះ ។

**មាត្រា ១០៤.-**

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវរាប់ចំនួនសន្លឹកឆ្នោតដែលមាននៅក្នុងហិបឆ្នោត ហើយផ្ទៀងផ្ទាត់ចំនួននេះ ជាមួយចំនួនអ្នកដែលបានមកបោះឆ្នោត ដែលរាប់ឃើញក្នុងបញ្ជីបោះឆ្នោត ។

ក្នុងករណីដែលសន្លឹកឆ្នោតក្នុងហិបឆ្នោតមានចំនួនខុសគ្នានឹងចំនួនអ្នកបោះឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់អោយរាប់ឡើងវិញ ។

ប្រសិនបើចំនួនខុសគ្នានៅតែមានដដែល ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះក្នុងកំណត់ហេតុ ។

បន្ទាប់មកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់អោយរាប់សន្លឹកឆ្នោត ដោយអនុលោមតាមបទបញ្ជា និងនីតិវិធី ។

**មាត្រា ១០៥.-**

ត្រូវចាត់ទុកជាបានការ សន្លឹកឆ្នោតណាដែលមានគូសសញ្ញាយកគណបក្សនយោបាយតែមួយ នៅលើសន្លឹកឆ្នោតដែលគណៈកម្មការិយាល័យបោះឆ្នោតចែកអោយ ។

ត្រូវទុកជាមោឃៈ សន្លឹកឆ្នោត :

១-ដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ ឬ

២-ដែលគ្មានគំនូសឬមានគំនូស តែគណៈកម្មការការិយាល័យបោះឆ្នោតពុំអាចសន្និដ្ឋានបាន ថាបោះអោយគណបក្សនយោបាយណាមួយ ឬ

៣-ដែលមានសញ្ញាដែលនាំអោយគេស្គាល់អ្នកបោះឆ្នោត ឬ

៤-ដែលមានរហែកឬខូច ។

សន្លឹកឆ្នោតដែលទុកជាមោឃៈក្នុងចំនុចទី ១ ទី២ ទី៣ ទី៤ ខាងលើនេះត្រូវកំណត់ដោយ បទបញ្ជា និងនីតិវិធី ។

**មាត្រា ១០៦.-**

បន្ទាប់ពីបានរាប់សន្លឹកឆ្នោតរួចហើយ គណៈកម្មការការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ ហេតុអំពីការរាប់សន្លឹកឆ្នោតនេះ ជាពីរច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះ ឆ្នោត ដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ ពុំបានការសន្លឹក ឆ្នោតដែលពុំបានប្រើ ប្រាស់បណ្តឹងជំទាស់ឬតវ៉ាប្រសិនបើមាន និងឯកសារផ្សេងៗទៀត និង មួយច្បាប់ទៀតបិទនៅការិយា-ល័យបោះឆ្នោត ។

សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ ឬតវ៉ា ឯកសារផ្សេងៗ ត្រូវច្រកដោយឡែកពីគ្នាក្នុងស្រោមសំបុត្រដែលបានចែកអោយ ។

កំណត់ហេតុស្តីពីការរាប់សន្លឹកឆ្នោតនេះ ត្រូវចុះហត្ថលេខាដោយប្រធាន និងសមាជិក គណៈ កម្មការការិយាល័យបោះឆ្នោត ។ តំណាងគណបក្សនយោបាយអាចចុះហត្ថលេខាជាសាក្សីលើកំណត់ ហេតុនេះបាន ។

**មាត្រា ១០៧.-**

ការបញ្ជូនការប្រគល់និងការទទួលកំណត់ហេតុត្រូវកំណត់ដោយបទបញ្ជានិងនីតិវិធី ។

**មាត្រា ១០៨.-**

តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិអាចចូលរួមជាសាក្សីក្នុងការប្រគល់ឬការទទួលកំណត់ហេតុបោះឆ្នោត ។

**មាត្រា ១០៩.-**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវប្រមូលកំណត់ហេតុ និងឯកសារ ទាំងអស់ពីគ្រប់គណៈកម្មការការិយាល័យបោះឆ្នោត រួចយកទៅជូនគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោតដោយផ្ទាល់ ។

**មាត្រា ១១០.-**

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវប្រមូលកំណត់ហេតុទាំងអស់ពីគ្រប់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត រួចធ្វើកំណត់ហេតុសរុបពីលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងរបស់ខ្លួន ។ កំណត់ហេតុនេះត្រូវធ្វើជាបីច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយភ្ជាប់ទៅជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការសន្លឹកឆ្នោតមិនបានការសន្លឹកឆ្នោតពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ឬតវ៉ាប្រសិនបើមាន ព្រមទាំងឯកសារផ្សេងៗ ទៀតមួយច្បាប់បិទនៅទីស្នាក់ការគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោតនិងមួយច្បាប់ទៀតទុកជាឯកសារ ។

**មាត្រា ១១១.-**

ប្រសិនបើមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬ អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវពិនិត្យ និង លើកយោបល់ជាបន្ទាន់ ភ្ជាប់ជាមួយនឹងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោតជូនទៅគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ដើម្បីពិនិត្យនិងសំរេចថាយកលទ្ធផលនៃការបោះឆ្នោតនេះជាបានការឬអោយបោះឆ្នោតឡើងវិញ ។

ការបោះឆ្នោតឡើងវិញ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំបី (៨) ថ្ងៃយ៉ាងយូរបន្ទាប់ពីការសំរេចនេះ ។

**មាត្រា ១១២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រមូលលទ្ធផលទាំងអស់មកពិនិត្យ ហើយធ្វើការសំរេចលើលទ្ធផលបោះឆ្នោត ។

បើភាពមិនប្រក្រតីមិនធ្ងន់ធ្ងរទេ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រកាសទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ។

ប្រសិនបើភាពមិនប្រក្រតីមានកម្រិតធ្ងន់ធ្ងរ ធ្វើអោយប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបដិសេធលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយជូនពត៌មានដល់គណបក្សនយោបាយ ។ ក្នុងករណីនេះ ការបោះឆ្នោតឡើងវិញនៅការិយាល័យបោះឆ្នោតនោះឬនៅការិយាល័យបោះឆ្នោតទាំងនោះ ត្រូវធ្វើប្រាំបី (៨) ថ្ងៃយ៉ាងយូរបន្ទាប់ពីការសំរេចនេះ ។

**មាត្រា ១១៣.-**

ក្រោយពីការពិនិត្យនិងសំរេចលើលទ្ធផលនៃការបោះឆ្នោត គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសតាំងតំណាងរាស្ត្រ ។

លទ្ធផលបណ្តោះអាសន្ននេះត្រូវផ្ញើមួយច្បាប់ថ្វាយព្រះមហាក្សត្រ និងមួយច្បាប់ផ្ញើជូនក្រុម-ប្រឹក្សាធម្មនុញ្ញ ។ គណបក្សនយោបាយដែលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិសុំសេចក្តីចម្លងលទ្ធផលបណ្តោះអាសន្នបាន ។

**មាត្រា ១១៤.-**

បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្នក្នុងរយៈពេលចិតសិបពីរ (៧២) ម៉ោងយ៉ាងយូរ គ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ា អំពីលទ្ធផលមួយផ្នែកឬលទ្ធផលទាំងអស់ នៃការបោះឆ្នោតទៅគណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោតឬ ទៅក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការដែលធ្វើខុសពីកាលបរិច្ឆេទ ដែលធ្វើខុសពីកន្លែងដែល មានការប្រព្រឹត្ត ខុសពីឈ្មោះនិងអាស័យដ្ឋាននៃសាក្សី ព្រមទាំងឯកសារឬភស្តុតាងដទៃទៀត ។

**មាត្រា ១១៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសំរេចលើបណ្តឹងតវ៉ា ក្នុងរយៈពេលសែសិបប្រាំបី (៤៨) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសំរេចថា បណ្តឹងតវ៉ាពុំអាចទទួលបាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

-បំពេញបែបបទនៃការបដិសេធដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅអ្នកប្តឹងតវ៉ា និងឬទៅគណបក្សនយោបាយ ។

-ផ្តល់ពត៌មានទៅអ្នកប្តឹងតវ៉ា និងឬគណបក្សនយោបាយថា អនុលោមតាមមាត្រា ១១៧ នៃច្បាប់នេះ សាមីខ្លួនឬគណបក្សនយោបាយមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលសែសិបប្រាំបី(៤៨)ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាពត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ១១៦.-**

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ថា បណ្តឹងតវ៉ាមានទម្ងន់ករណីសមហេតុផល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈ ដើម្បីសំរេច ។ ក្នុងករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយកាលបរិច្ឆេទទីកន្លែងនៃសវនាការផ្តល់ពត៌មានទៅអ្នកប្តឹងតវ៉ានិងឬទៅគណបក្សនយោបាយនិងជូន ពត៌មានទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

អ្នកប្តឹងតវ៉ា និងឬគណបក្សនយោបាយនិងសមាជិកគណៈកម្មការរៀបចំការបោះឆ្នោត និងឬគណៈកម្មការរៀបចំការបោះឆ្នោតដែលពាក់ព័ន្ធត្រូវមានវត្តមាននៅក្នុងសវនាការនេះ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមតាមពាក្យបណ្តឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

-បដិសេធលទ្ធផលនៅការិយាល័យបោះឆ្នោតនោះ ឬ នៅការិយាល័យបោះឆ្នោតទាំងនោះ ហើយរៀបចំអោយមានការបោះឆ្នោតឡើងវិញ នៅកន្លែងនោះឬកន្លែងទាំងនោះក្នុងរយៈ ពេលប្រាំបី (៨) ថ្ងៃយ៉ាងយូរបន្ទាប់ពីការសំរេចនេះ ។

-បំពេញបែបបទ នៃការយល់ព្រមដោយបញ្ជាក់ពីមូលហេតុនិងកាលបរិច្ឆេទនៃការយល់ព្រម ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីយល់ព្រមមួយច្បាប់ទៅអ្នកប្តឹងតវ៉ា និង ឬគណបក្ស នយោបាយ ។

-ផ្ញើសេចក្តីចម្លង នៃសេចក្តីយល់ព្រមមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាពត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពុំយល់ព្រមតាមបណ្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

-បំពេញបែបបទនៃការបដិសេធដោយបញ្ជាក់ពីមូលហេតុនិងកាលបរិច្ឆេទ នៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធទៅអ្នកប្តឹងតវ៉ា និងឬគណបក្សនយោបាយ ។

-ផ្តល់ពត៌មានដល់អ្នកប្តឹងតវ៉ា និងឬគណបក្សនយោបាយថា អនុលោមតាមមាត្រ ១១៧ នៃច្បាប់នេះ សាមីខ្លួនឬគណបក្សនយោបាយនោះ មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលសែសិបប្រាំបី(៤៨)ម៉ោងយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាពត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ១១៧.-**

ជនណា និង ឬគណបក្សនយោបាយណាដែលបណ្តឹងតវ៉ារបស់ខ្លួនត្រូវបានបដិសេធ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជននោះ និង ឬគណបក្សនយោបាយនោះមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខអក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលសែសិបប្រាំបី (៤៨) ម៉ោងយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីការបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេលពីដប់(១០)ថ្ងៃទៅម្ភៃ (២០) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ការសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាការសំរេចចុងក្រោយ ។

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសំរេចថាបណ្តឹងតវ៉ាពុំអាចទទួលបានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ :

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុនិងកាលបរិច្ឆេទនៃការ បដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅអ្នកប្តឹងតវ៉ា និងឬទៅគណបក្សនយោបាយ និងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

-ផ្សព្វផ្សាយសេចក្តីសំរេច និងទុកមួយច្បាប់ជាឯកសារ ។

-ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ថា បណ្តឹងតវ៉ាមានទឡ្ហីករណ៍សមហេតុផល ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបើកសវនាការជាសាធារណៈ ដើម្បីពិនិត្យនិងសំរេចក្នុងរយៈពេលដប់ (១០) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ក-ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ :

-បំពេញបែបបទនៃការយល់ព្រមដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការយល់ព្រម ។

-ផ្តល់សេចក្តីចម្លងនៃការយល់ព្រមមួយច្បាប់ទៅអ្នកប្តឹងតវ៉ា និងឬទៅគណបក្សនយោបាយ ។

-ចេញសេចក្តីសំរេចអោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយអោយរៀបចំការបោះឆ្នោតឡើងវិញនៅកន្លែងនោះ ឬនៅកន្លែងទាំងនោះ ក្នុងរយៈពេលប្រាំបី (៨) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសំរេចនេះ ។

-ផ្សព្វផ្សាយសេចក្តីសំរេចនិងរក្សាទុកមួយច្បាប់ជាឯកសារ ។

ខ-ក្នុងករណីដែលក្រុមប្រឹក្សាធម្មនុញ្ញពុំយល់ព្រមតាមបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ :

-បំពេញបែបបទនៃការបដិសេធដោយបញ្ជាក់ពីមូលហេតុនិងកាលបរិច្ឆេទ នៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធទៅអ្នកប្តឹងតវ៉ា និង ឬទៅគណបក្សនយោបាយ និងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

-ផ្សព្វផ្សាយសេចក្តីបដិសេធ និងទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ១១៨.-**

ក្រោយពីបណ្តឹងតវ៉ាត្រូវបានសំរេចជាស្ថាពរនិងក្រោយពីបានទទួលលទ្ធផល នៃការបោះឆ្នោតទាំងអស់រួមទាំងលទ្ធផល នៃការបោះឆ្នោតដែលត្រូវធ្វើឡើងវិញ ប្រសិនបើមានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាផ្លូវការលទ្ធផល នៃការបោះឆ្នោតហើយ កំណត់ចំនួនអាសនៈសំរាប់គណបក្សនយោបាយនីមួយៗ តាមមណ្ឌលនីមួយៗ ដោយគិតតាម ចំនួនសន្លឹកឆ្នោតបានការ ។

ការបែងចែកអាសនៈដែលនៅសល់តាមមណ្ឌលនីមួយៗ ត្រូវអនុវត្តតាមវិធីបែងចែកដោយមធ្យមភាគធំជាងគេ ។

ការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រត្រូវអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងអនុវត្តតាមលំដាប់លេខរៀង ដូចមានចែងក្នុងមាត្រា ៣៨នៃច្បាប់នេះ ។

ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតមានអ្នកជាប់ឆ្នោតទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពតំណាងរាស្ត្រ បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវបានប្រកាសថា ជាប់ឆ្នោតជាតំណាងរាស្ត្ររបស់សាមីគណបក្សនយោបាយ ។

**មាត្រា ១១៩.-**

ការរាប់ចំនួនថ្ងៃតវ៉ានិងការសំរេចលើបណ្តឹងតវ៉ា ដូចមានចែងក្នុងជំពូកទី៤ ជំពូកទី៦ និងជំពូកទី៨ នៃច្បាប់នេះ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

## ជំពូកទី ៩

## ករណីជ្រើសតាំងជំនួសសមាជិករដ្ឋសភា

**មាត្រា ១២០.-**

ក្នុងករណីដែលសមាជិករដ្ឋសភាទទួលអនិច្ចកម្មឬលាលែង ឬប្រាសចាកសមាជិកភាពរដ្ឋសភាដែលកើតឡើងប្រាំមួយ(៦)ខែ យ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះអាចស្នើជ្រើសរើសតាំងសមាជិកថ្មីជំនួស ដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះតាមលេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៃមណ្ឌលរបស់សាមីខ្លួននោះមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ។

ក្នុងករណីដែលសមាជិកគណបក្សនយោបាយមួយសុំលាលែងចេញពីគណបក្សនោះ សាមីខ្លួនត្រូវបាត់បង់សមាជិកភាពជាតំណាងរាស្ត្រដោយស្វ័យប្រវត្តិ ។ បើការលាលែងនេះមានរយៈពេលប្រាំមួយ (៦)ខែយ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួស ។ ហើយការជ្រើសតាំងជំនួសនេះត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី១ មាត្រា ១២០ នៃច្បាប់នេះ ។

## ជំពូកទី ១០

## ថវិកា

**មាត្រា ១២១.-**

ត្រូវបានបង្កើតគណនីពិសេសរបស់ធនាគារជាតិ ជាគណនីមូលនិធិទាយជ្ជទានការបោះឆ្នោតសំរាប់អោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យកទៅចាត់ចែងក្នុងកិច្ចការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អនុលោមតាមច្បាប់ហិរញ្ញវត្ថុ ។

មូលនិធិទាយជ្ជទានការបោះឆ្នោតដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការក្រៅរដ្ឋាភិបាល និង ចំណូលស្របច្បាប់ផ្សេងៗត្រូវបញ្ចូលក្នុងថវិកាជាតិ ដើម្បីផ្តល់ផ្ទាល់អោយទៅគណនីពិសេសនេះ ។

ហិរញ្ញប្បទានក្រៅប្រទេសមួយចំនួនសំរាប់ការបោះឆ្នោតអាចអនុវត្តដោយប្រតិបត្តិការក្រៅរតនាគារជាតិ ។

## ជំពូកទី ១១

## ទោសប្បញ្ញត្តិ

**មាត្រា ១២២.-**

ត្រូវស្តីបន្ទោសឬបណ្តេញពីការងារ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះភ្នាក់ងារចុះឈ្មោះបោះឆ្នោតណាដែលប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

-បានចុះឈ្មោះ ប៉ុន្តែមិនព្រមប្រគល់ប័ណ្ណបោះឆ្នោតជូនប្រជាពលរដ្ឋ ។

-បានចេញប័ណ្ណបោះឆ្នោតដោយចេតនាដល់អ្នកដែលពុំទាន់គ្រប់អាយុបោះឆ្នោត ឬ ដល់អ្នកដែលពុំបំពេញល័ក្ខខ័ណ្ឌគ្រប់គ្រាន់អាចចុះឈ្មោះបោះឆ្នោតបាន ។

-បានចុះឈ្មោះ និង បានប្រគល់ប័ណ្ណដោយចេតនាទៅអ្នកដែលត្រូវបានដកសិទ្ធិបោះ ឆ្នោត ។

-រារាំងប្រជាពលរដ្ឋដែលមានអាយុចាប់ពីដប់ប្រាំបី (១៨) ឆ្នាំឡើងទៅមិនអោយចុះឈ្មោះបោះឆ្នោត ។

-រារាំងប្រជាពលរដ្ឋមិនអោយទទួលប័ណ្ណបោះឆ្នោត ក្រោយពេលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ ។

**មាត្រា ១២៣.-**

ត្រូវបដិសេធពាក្យស្នើសុំឈរឈ្មោះបោះឆ្នោតរបស់សាមីខ្លួន ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៣ ឬ មាត្រា ៣៤ នៃច្បាប់នេះ ។

មាត្រា ១២៤.-

ត្រូវដកហូតប័ណ្ណបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួនឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀលទៅម្ភៃប្រាំលាន (២៥.០០០.០០០) រៀលដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណានិងឬគណបក្សនយោបាយណាដែលបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម :-

-ប្រើកម្លាំង ឬអំពើហិង្សាឬបំភិតបំភ័យមិនអោយប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោតឬទៅទទួលប័ណ្ណបោះឆ្នោត ។

-ញុះញង់អ្នកគាំទ្រ ឬ អ្នកបោះឆ្នោតអោយប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជនឬទៅលើគណបក្សនយោបាយដទៃ ។

-ធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសច្ចាអោយគេបោះឆ្នោតអោយគណបក្សនយោបាយរបស់ខ្លួនឬអោយគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត ។

-ប្រើកម្លាំងឬអំពើហិង្សា ដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនអោយទៅបោះឆ្នោតឬឈរឈ្មោះជាបេក្ខជន ។

-រារាំងបេក្ខជន និង អ្នកគាំទ្រគណបក្សនយោបាយមិនអោយឃោសនាបោះឆ្នោតតាមកាលកំណត់ ។

-ប្រើកម្លាំងឬហិង្សាឬបំភិតបំភ័យ ប្រើពាក្យសំដីប្រមាថមើលងាយធ្វើអោយមានការភ័យខ្លាចការភាន់ច្រឡំធ្វើអោយច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

-បង្កការរំខានមិនអោយដំណើរការបោះឆ្នោតបាន ។

-បង្កការរំខានមិនអោយរាប់សន្លឹកឆ្នោតបាន ។

-ធ្វើអោយខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។

-ទិញសន្លឹកឆ្នោតដោយសំភារៈឬដោយប្រាក់កាស ។

**មាត្រា ១២៥.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬនិងដកហូតប័ណ្ណបោះឆ្នោត សំរាប់រយៈពេលប្រាំ (៥)ឆ្នាំ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំពោះសមាជិក គណៈកម្មាធិការជាតិ សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោតឬប្រើកលល្បិច ដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

**មាត្រា ១២៦.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ដល់ហាសិបលាន (៥០.០០០.០០០)រៀលឬនិងត្រូវបញ្ឈប់ពីការងារបោះឆ្នោតជារៀងរហូត ចំពោះភ្នាក់ងារឬ សមាជិក ឬបុគ្គលិកនៃគណៈកម្មាធិការជាតិ ឬភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតណាដែលប្រព្រឹត្តល្មើសនឹងវាក្យខ័ណ្ឌទី ២ មាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ១២៧.-**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៩៥ ឬមាត្រា ១០០ នៃ ច្បាប់នេះ ។ ក្នុងករណីដែលពុំព្រមអនុវត្តតាមការព្រមាននេះ ត្រូវឃាត់ខ្លួននិងដកហូតអាវុធសំរាប់រយៈពេលសែសិបប្រាំបី(៤៨)ម៉ោងដោយភ្នាក់ងារមានសមត្ថកិច្ច និងផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០)រៀល ។

ប្រសិនបើជនល្មើសនោះជាមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

-ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន ដើម្បីអោយដាក់វិន័យរដ្ឋបាលចាប់ពីការដាក់អោយទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែង យោលទៅតាមកំរិតនៃ បទល្មើស ។

-លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដកហូតប័ណ្ណបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារឬសមាជិក ឬជាបុគ្គលិករបស់គណៈកម្មាធិការជាតិ ឬ គណៈកម្មការ ខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ឬគណៈកម្មការការិយាល័យបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារភ្លាម និងមិនអោយចូលបំរើការ

ងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សំរាប់រយៈពេលដប់ (១០) ថ្ងៃ ចាប់ពីសម័យបោះឆ្នោតនេះទៅបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រានេះ ។

**មាត្រា ១២៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវដកហូតប័ណ្ណបោះឆ្នោតសំរាប់រយៈពេលប្រាំ (៥) ឆ្នាំ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន អោយដាក់វិន័យរដ្ឋបាលចាប់ពីដាក់អោយទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែង ចំពោះមន្ត្រីរាជការឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៩ នៃ ច្បាប់នេះ ។

**មាត្រា ១២៩.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ដល់ដប់លាន (១០.០០០.០០០) រៀលឬនិងត្រូវដកហូតប័ណ្ណបោះឆ្នោតសំរាប់រយៈពេលប្រាំ (៥) ឆ្នាំ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំពោះជនណាដែលបង្ខាប់បញ្ជាឬលួងលោម បោកបញ្ឆោតអោយ អ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយ ផ្សេងទៀតក្នុងពេលបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារឬជាបុគ្គលិកឬជាសមាជិកគណៈកម្មាធិការជាតិ ឬរបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និង មិនអោយចូលបំរើការងារជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សំរាប់រយៈពេលដប់ (១០) ឆ្នាំចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនប្រព្រឹត្តល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី២ នៃមាត្រានេះ ។

**មាត្រា ១៣០.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតឬនិងត្រូវដកហូតប័ណ្ណបោះឆ្នោតសំរាប់រយៈពេលប្រាំ (៥) ឆ្នាំ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតចំពោះជនណាដែលធ្វើអោយរបើក

ហិបឆ្នោត ដាច់ ឬរហែក ឬរបូតឃ្លុំ ឬគ្រឿងសំគាល់សំរាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើអោយបាត់ ឬលួច ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ប្រសិនបើជនល្មើសនោះ ជាភ្នាក់ងារជាបុគ្គលិកឬជាសមាជិករបស់គណៈកម្មាធិការជាតិ ឬរបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និង មិនអោយសាមីខ្លួនចូលបំរើការងារជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ សំរាប់រយៈពេលដប់ (១០) ឆ្នាំគិតចាប់ពីសម័យ បោះឆ្នោតនេះទៅ ។

ប្រសិនបើជនល្មើសនោះជាបេក្ខជនវិញ ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ នៃមាត្រានេះ ។

**មាត្រា ១៣១.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬនិងត្រូវដកហូតប័ណ្ណបោះឆ្នោតសំរាប់រយៈពេលប្រាំ (៥) ឆ្នាំ ឬលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំពោះជនណា ឬ គណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៣ ឬមាត្រា ៧៦ នៃច្បាប់នេះ ។

**មាត្រា ១៣២.-**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៧ ឬវាក្យខ័ណ្ឌទី២ នៃ មាត្រា ៧៨ នៃច្បាប់នេះ ។

ក្នុងករណីដែលនៅតែពុំព្រមអនុវត្តតាម ត្រូវដកហូតប័ណ្ណបោះឆ្នោតសំរាប់រយៈពេលប្រាំ (៥) ឆ្នាំ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនអោយដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់អោយទំនេរដោយគ្មានបៀវត្សរហូតដល់បណ្តេញចេញពីមុខតំណែង ឬនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ដល់ពីរលាន (២.០០០.០០០) រៀល ។

**មាត្រា ១៣៣.-**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧២ នៃច្បាប់នេះ ។

ក្នុងករណីដែលនៅតែពុំព្រមអនុវត្តតាម ត្រូវដកហូតប័ណ្ណបោះឆ្នោតសំរាប់រយៈពេលប្រាំ (៥) ឆ្នាំលុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយឬនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ដល់ដប់លាន(១០.០០០.០០០) រៀល ។

## ជំពូកទី ១២

## អន្តរប្បញ្ញត្តិ

**មាត្រា ១៣៤.-**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់នីតិកាលទី ២ នៃរដ្ឋសភាត្រូវប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ។

**មាត្រា ១៣៥.-**

ក្រោយពីច្បាប់នេះចូលជាធរមាន ដើម្បីការបោះឆ្នោតនៅថ្ងៃអាទិត្យទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ចំនួនអាសនៈក្នុងរដ្ឋសភា ត្រូវកំណត់ត្រឹមមួយរយម្ភៃពីរ (១២២) ។ ចំនួនអាសនៈនេះត្រូវផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ ។

**មាត្រា ១៣៦.-**

ក្រោយពីច្បាប់នេះចូលជាធរមាន ដើម្បីការបោះឆ្នោតនៅថ្ងៃអាទិត្យទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨ ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ តែងតាំងជាបន្ទាន់ដោយព្រះរាជក្រឹត្យតាមសំណើរបស់គណៈរដ្ឋមន្ត្រី ក្រោយពីបានទទួលការ យល់ព្រមពីរដ្ឋសភា ។

ក្រសួងមហាផ្ទៃមានភារកិច្ចដាក់ជូនគណៈរដ្ឋមន្ត្រីជាបន្ទាន់ នូវសេចក្តីព្រាងសមាសភាព នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៣៧.-**

ក្រោយពីច្បាប់នេះចូលជាធរមាន ដើម្បីការបោះឆ្នោតនៅថ្ងៃអាទិត្យទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ប្រជាពលរដ្ឋមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រោយពីបានបំពេញលក្ខខ័ណ្ឌ ១.២.៣.៥ មាត្រា ៣៣ នៃច្បាប់នេះ និងបន្ទាប់ពីបានស្នាក់នៅជា អចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិចមួយ (១) ខែ គិតមកដល់ថ្ងៃបើកការចុះបញ្ជី បោះឆ្នោត ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

**មាត្រា ១៣៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣៩.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

**ស ខេង , យូ ហុកគ្រី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

**អ៊ឹង ហួត , ហ៊ុន សែន**

* * *